លេខ ៨ ចេញផ្សាយថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២១

# ព្រឹត្តិបត្រព័ត៌មានប្រចាំខែតុលា ឆ្នាំ២០២១

**និយ័តករបរធនបាលកិច្ច**
**គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ**
**បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា**

**មាតិកា**

- វេទិកាស្តីពី "កាតព្វកិច្ចគណនេយ្យនិងសវនកម្ម និងអត្ថប្រយោជន៍ចំពោះសេដ្ឋកិច្ច"

## វេទិកាស្តីពី "កាតព្វកិច្ចគណនេយ្យនិងសវនកម្ម និងអត្ថប្រយោជន៍ចំពោះសេដ្ឋកិច្ច"

នាព្រឹកថ្ងៃព្រហស្បតិ៍ ៧រោច ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី២៨ ខែតុលា ឆ្នាំ ២០២១ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានចូលរួមចែករំលែកចំណាប់អារម្មណ៍ក្នុងនាម **ន.ប.ធ.** លើកាតព្វកិច្ចគណនេយ្យនិងសវនកម្មរបស់តួអង្គពាក់ព័ន្ធក្នុង សេដ្ឋកិច្ចនៅក្នុងវេទិកាស្តីពី "កាតព្វកិច្ចគណនេយ្យនិងសវនកម្ម និងអត្ថប្រយោជន៍ចំពោះសេដ្ឋកិច្ច" ដែលសហការរៀបចំដោយនិយ័តករទាំង ៥ ក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដែលក្នុងនោះមាននិយ័តករបរធនបាលកិច្ច និយ័តករគណនេយ្យនិងសវនកម្ម និយ័តករមូលបត្រកម្ពុជា និយ័តករធានារ៉ាប់រង-កម្ពុជា និយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ និងស្ថាប័នពាក់ព័ន្ធ តាមរយៈគំនិតផ្តួចផ្តើមរបស់និយ័តករគណនេយ្យនិងសវនកម្ម។




រូបភាពក្នុងវេទិកាស្តីពី "កាតព្វកិច្ចគណនេយ្យនិងសវនកម្ម និងអត្ថប្រយោជន៍ចំពោះសេដ្ឋកិច្ច" ក្រោមវត្តមានដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ ដារ៉ា**។